# ពេលនឹងមកដល់

*ដោយអែលឌើរ អិល វីតនី ក្លេតុន*
*នៃគណៈប្រធាននៃពួកចិតសិបនាក់*

ខ្ញុំធ្លាប់បម្រើជាអ្នកផ្សាយសាសនាវ័យក្មេងអស់រយៈពេលជាច្រើនខែក្នុងតំបន់កណ្ដាលទីក្រុង លីម៉ា ប្រទេសប៉េរូ ។ ជាលទ្ធផល ខ្ញុំបានចូលដល់កន្លែងដ៏សំខាន់ៗក្នុងទីក្រុងលីម៉ាជាច្រើនដង ។ វិមានរដ្ឋា-ភិបាលជាលំនៅ និងការិយាល័យរបស់ប្រធានាធិបតីប្រទេសប៉េរូ ។ ដៃគូខ្ញុំ និងខ្ញុំបានអញ្ជើញមនុស្សជាច្រើននៅក្នុងវិមាននោះ ឲ្យស្ដាប់ដំណឹងល្អដែលបានស្ដារឡើងវិញ ។ ជាញឹកញាប់ខ្ញុំឆ្ងល់ថាតើការចូលក្នុងវិមាននោះនឹងមានទិដ្ឋភាពយ៉ាងណាទៅ ប៉ុន្តែការគិតនោះហាក់ដូចជានឹងពុំកើតឡើងឡើយ ។

កាលពីឆ្នាំមុនអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ជាមួយពីរបីនាក់ផ្សេងទៀត និងរូបខ្ញុំបានជួបជាមួយនឹងលោក អាឡាន់ ហ្គាសៀដែលជាប្រធានាធិបតីប៉េរូក្នុងវិមានរដ្ឋាភិបាលនោះ ។ យើងត្រូវបានទទួលស្វាគមន៍ដ៏កក់ក្ដៅពីសំណាក់លោកប្រធានាធិបតី និងបានបង្ហាញឲ្យឃើញបន្ទប់ដ៏ស្រស់ស្អាតទាំងឡាយក្នុងវិមាននោះ ។ ចម្ងល់របស់ខ្ញុំកាលជាអ្នកផ្សាយសាសនាវ័យក្មេងអំពីវិមាននេះត្រូវបានបំពេញតាមរបៀបមួយដែលខ្ញុំមិនដែលសង្ឃឹមថាអាចកើតឡើងឡើយកាលពីឆ្នាំ 1970 ។

អ្វីៗត្រូវបានផ្លាស់ប្ដូរនៅប្រទេសប៉េរូ តាំងពីខ្ញុំធ្វើជាអ្នកផ្សាយសាសនា ជាពិសេសសម្រាប់សាសនាចក្រ ។ កាលនោះមានតែសមាជិកសាសនាប្រហែលជា 11,000 នាក់ និងស្តេកមួយប៉ុណ្ណោះ ។ បច្ចុប្បន្ននេះ មានសមាជិកជាង 300,000 នាក់ និងមានស្តេកជិត 100 កន្លែង ។ ក្នុងទីក្រុងដែលធ្លាប់មានសមាជិកមួយក្រុមតូច ឥឡូវនេះគឺជាស្តេកដ៏សកម្ម និងមានសាលាប្រជុំដ៏ទាក់ទាញនានា ដែលបានលម្អដល់ទឹកដីនោះ ។ ដូចជាអ្វីដែលបានកើតឡើងនៅក្នុងប្រទេសជាច្រើនទៀតជុំវិញពិភពលោកដែរ ។

ការរីកចម្រើនរបស់សាសនាចក្រដ៏គួរឲ្យកត់សម្គាល់នេះបង្ហាញពីការពន្យល់ ។ ខ្ញុំនឹងចាប់ផ្ដើមដោយការព្យាករណ៍ពីព្រះគម្ពីរសញ្ញាចាស់ ។

ដានីយ៉ែលជាទាសករសាសន៍ហេព្រើរម្នាក់ក្នុងទីក្រុងបាប៊ីឡូន ។ គាត់ត្រូវបានផ្ដល់ឱកាសឲ្យបកស្រាយសុបិននៃស្ដេចនេប៊ូក្នេសា ។ ដានីយ៉ែលបានទូលសុំដល់ព្រះឲ្យបើកសម្ដែងដល់គាត់ពីសុបិន និងអត្ថន័យរបស់វា ហើយការអធិស្ឋានរបស់គាត់ត្រូវបានឆ្លើយតប ។

គាត់បានទូលស្ដេចនេប៊ូក្នេសាថា « តែមានព្រះមួយអង្គដែលគង់នៅស្ថានសួគ៌ ទ្រង់ សម្ដែងឲ្យយល់សេចក្ដីអាថ៌កំបាំងបាន ហើយទ្រង់បានសម្ដែងឲ្យព្រះករុណានេប៊ូក្នេសាបានជ្រាបពីការដែលត្រូវកើតមកថយក្រោយ ។ ការជាក់ស្ដែងដែលទ្រង់បានឃើញកំពុងផ្ទំលក់គឺយ៉ាងនេះ » ។

គាត់បាននិយាយថា ស្ដេចបានទតឃើញរូបដ៏គួរឲ្យភ័យខ្លាចដោយមានក្បាល ដងខ្លួន ដៃ ជើង និងប្រអប់ជើង ។ ថ្មត្រូវបានដាប់ចេញពីភ្នំដោយឥតដៃណាធ្វើ ហើយរមៀលទៅមុខបន្តិចម្ដងៗ ។ ថ្មទង្គិចនឹងរូបនោះ បែកទៅជាដុំតូចៗ «ឯថ្មដែលទង្គិចនឹងរូបនោះក៏ត្រឡប់ទៅជាភ្នំយ៉ាងធំ នៅពេញផែនដីទាំងដុំមូល » ។

ដានីយ៉ែលបានពន្យល់ថារូបនោះតំណាងឲ្យនយោបាយរបស់នគរនាពេលអនាគត ហើយថា « រីឯនៅគ្រានៃស្ដេចទាំងនោះ ស្ដេច [ នាពេលអនាគតទាំងនោះ ] ព្រះនៃស្ថានសួគ៌ទ្រង់នឹងតាំងនគរមួយឡើយ ដែលមិនត្រូវបំផ្លាញឡើយ ហើយនគរនោះនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច » ។[1]

ឥឡូវនេះខ្ញុំនឹងណែនាំទៅរកបទគម្ពីរមួយចេញមកពីសម័យទំនើប ។ ការយាងមកលើកដំបូងរបស់ព្យាការី មរ៉ូណៃដល់យ៉ូសែប ស៊្មីធ កាលពីឆ្នាំ 1823 បានប្រាប់លោកថាព្រះទ្រង់មានកិច្ចការឲ្យ[ លោក ]ធ្វើ ហើយថាឈ្មោះ [ របស់លោក ] នឹងមានដើម្បីសេចក្ដីល្អ និងសេចក្ដីអាក្រក់ក្នុងគ្រប់ទាំងសាសន៍គ្រប់ពូជន៍មនុស្ស ហើយគ្រប់ទាំងភាសា» ។ សារលិខិតរបស់មរ៉ូណៃប្រាកដជាត្រូវធ្វើឲ្យយ៉ូសែបដែលទើបតែមានអាយុ 17 ឆ្នាំ មានការភ្ញាក់ផ្អើល ។

កាលពីឆ្នាំ 1831 ព្រះអម្ចាស់បានមានបន្ទូលទៅយ៉ូសែបថា កូនសោទាំងឡាយនៃនគរព្រះត្រូវបាន « ផ្ទុកផ្ដាក់ដល់មនុស្សនៅលើផែនដី »[2] ម្ដងទៀត ។ ទ្រង់បានមានបន្ទូលថា « ដំណឹងល្អ [នឹង ] ត្រូវរមៀលចេញទៅដល់ទីបំផុតផែនដីដូចថ្មដែលដាប់ផ្ដាច់ចេញពីភ្នំឥតដៃណាធ្វើ... រហូតដល់ពេញផែនដីទាំងមូល » [3] ដូចដែល ដានីយ៉ែលបានប្រាប់ដល់ស្ដេចនេប៊ូក្នេសា ។

ក្នុងឆ្នាំ 1898 ប្រធាន វិលហ្វូឌ វូឌ្រុព្វ បានរៀបរាប់ប្រាប់ពីបទពិសោធន៍មួយដែលលោកបានមានកាលជាសមាជិកថ្មីមួយរូបកាលពីឆ្នាំ 1834 នៅក្នុងការប្រជុំបព្វជិតភាពនៅជិតទីក្រុងខឺតឡង់ ។ លោកបានលើកលើងថា ៖ « ព្យាការីបានហៅអស់អ្នកដែលកាន់បព្វជិតភាពឲ្យជួបជុំគ្នានៅក្នុងសាលាតូចមួយដែលពួកគេមាននៅទីនោះ ។ សាលានោះគឺជាផ្ទះតូចមួយ មានទំហំប្រហែលជា 18 ម៉ែត្របួនជ្រុង។ នៅពេលយើងបានជួបជុំគ្នាព្យាការីបានហៅពួកអែលឌើរនៃអ៊ីស្រាអែលឲ្យថ្លែងទីបន្ទាល់ពីការណ៍នេះ ។...

នៅពេលពួកគេបានស្តាប់ចប់សព្វគ្រប់ហើយព្យាការីបានមានប្រសាសន៍ថា ‹ បងប្អូនប្រុស ខ្ញុំត្រូវបានស្អាង និងណែនាំជាច្រើននៅក្នុងទីបន្ទាល់របស់អ្នកនៅទីនេះនាយប់នេះ ប៉ុន្តែខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នានៅចំពោះព្រះអម្ចាស់ថា អ្នកមិនបានដឹងច្រើនទេពីជោគវាសនានៃនគរ និងសាសនាចក្រនេះជាងទារកដែលនៅលើភ្លៅម្តាយរបស់វានោះទេ ។ អ្នកមិនយល់ទេ ។... វាគ្រាន់តែជាចំនួនតិចតួចនៃបព្វជិតភាពដែលអ្នកបានឃើញនៅទីនេះនាយប់នេះ តែសាសនាចក្រនេះនឹងមានពាសពេញ អាមេរិកខាងជើង និងខាងត្បូង---វានឹងមានពេញពិភពលោក › » ។[4]

ការព្យាករណ៍ទាំងនេះមានន័យថា៖

- *នគរព្រះដូចជាថ្មដែលដាប់ផ្តាច់ចេញពីភ្នំនឹងមានពាសពេញផែនដី*
- *ឈ្មោះរបស់យ៉ូសែប ស៊្មីធនឹងត្រូវបានស្គាល់ពេញពិភពលោក ហើយ*
- *សាសនាចក្រនឹងមានពាសពេញទ្វីបអាមេរិក និងពេញពិភពលោក*

វាហាក់ដូចជាការដ៏គួរឲ្យអស់សំណើចជាច្រើនឆ្នាំមកហើយ ។ ក្រុមដ៏តូចនៃពួកអ្នកជឿរស់នៅដោយពិបាកនៅផ្នែកមួយនៃប្រទេសអាមេរិកដែលគ្មាននរណាកាន់កាប់ ហើយរើចេញជារៀងរាល់ពីរបីឆ្នាំម្តងដើម្បីគេចចេញពីការបៀតបៀន ដែលមើលដូចជាពុំមែនជាគ្រឹះនៃជំនឿដែលនឹងឆ្លងព្រំប្រទល់អន្តរជាតិ ហើយទម្លុះដល់បេះដូងគ្រប់ទីកន្លែងទាំងអស់នោះទេ ។

ប៉ុន្តែនោះគ្រាន់តែជាអ្វីដែលបានកើតឡើងប៉ុណ្ណោះ ។ សូមឲ្យខ្ញុំផ្តល់ដល់អ្នកនូវឧទាហរណ៍មួយ ។

នាថ្ងៃបុណ្យគ្រីស្ទម៉ាសក្នុងឆ្នាំ 1925 នៅទីក្រុង ប៊ូអេណុស អៃរ៉េស អែលឌើរ មេលវិន ជី បាឡាដ បានឧទ្ទិសដល់ទ្វីបអាមេរិកខាងត្បូងទាំងមូលសម្រាប់ការប្រកាសដំណឹងល្អ ។ នៅខែ សីហា ឆ្នាំ 1926 អ្នកប្រែចិត្តជឿមួយក្រុមតូចបានទទួលបុណ្យជ្រមុជទឹក ។ ពួកគេជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដំបូងគេនៅអាមេរិកខាងត្បូង ។ គឺ 85 ឆ្នាំកន្លងផុតទៅហើយ ។ មានស្តេកនៃស៊ីយ៉ូនចំនួន 23 កន្លែង ក្នុងទីក្រុង ប៊ូអេណុស អៃរ៉េស ពេលនេះ រួមជាមួយនឹងស្តេកជាច្រើនទៀត ព្រមទាំងសមាជិកសាសនាចក្ររាប់ពាន់នាក់ទៀតនៅក្នុងទីក្រុង និងជាយក្រុងពាសពេញប្រទេសអាហ្សង់ទីន ។

ឥឡូវនេះ មានស្តេកជាង 600 កន្លែង និងមានសមាជិកសាសនាចក្រជាងពីរបីលាននាក់ទូទាំងអាមេរិកខាងត្បូង ។ ខណៈពេលដែលយើងមើលនគរព្រះកំពុងតែរីកពាសពេញទ្វីប ហើយឈ្មោះនៃយ៉ូសែប ស៊្មីធកំពុងតែត្រូវបានផ្សព្វផ្សាយទាំងតាមរយៈយើង និងអ្នករិៈគន់លោកនៅក្នុងប្រទេសនានាដែលប្រហែលជាលោកពុំធ្លាប់ឮសោះក្នុងអំឡុងពេលមានជីវិតរបស់លោកនោះ ។

មានស្តេកជិត 3,000 កន្លែងក្នុងសាសនាចក្រទូទាំងពិភពលោកសព្វថ្ងៃនេះពីរដ្ឋបូស្តុនដល់ទីក្រុងបាងកក និងទីក្រុងម៉ិកស៊ិកដល់ទីក្រុងម៉ូស្គូ ។ យើងមានវួដ និងសាខាចំនួន29,000 កន្លែង ។ នៅក្នុងប្រទេសជាច្រើនមានស្តេករឹងមាំជាច្រើន ដែលសមាជិកជាច្រើនមានជីដូនជីតារបស់ពួកគេជាអ្នកផ្លាស់ប្រែចិត្តជឿ ។ នៅកន្លែងផ្សេងៗទៀត មានក្រុមតូចៗនៃពួកសមាជិកថ្មីជួបជុំគ្នាជាសាខាសាសនាចក្រដ៏តូចនៅក្នុងផ្ទះជួលទាំងឡាយ ។ ជារៀងរាល់ឆ្នាំសាសនាចក្រពង្រីកកាន់តែឆ្ងាយទៅពាសពេញពិភពលោក ។

ការព្យាករណ៍អំពីការរីកពាសពេញពិភពលោក និងការស្គាល់ទូទាំងពិភពលោកទាំងនេះ ៖ តើវាមិនសមហេតុផលឬ? នេះឆ្លើយនឹងសំណួរមុន ។ តើវាមិនទំនងឬ? ដោយគ្មានការសង្ស័យ ។ តើមិនអាចទៅរួចទេឬ ? ប្រាកដណាស់វាមិនអាចទេ ។ វាកំពុងតែកើតឡើងនៅនឹងមុខរបស់យើង ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានអង្កេតឃើញថា ៖ « មានគ្រាមួយបាននិយាយថា ព្រះអាទិត្យនឹងមិនលិចចុះនៅលើចក្រភពអង់គ្លេសទេ ។ ចក្រភពនោះឥឡូវត្រូវបានចុះថយ ។ ប៉ុន្តែជាការពិតណាស់ព្រះអាទិត្យមិនដែលលិចនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់នោះទេ នៅពេលវាកំពុងតែដក់ជាប់នៅក្នុងជីវិតរបស់មនុស្សជាច្រើននៅទូទាំងផែនដី ។

« ហើយនេះគឺគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ យើងបានចាប់ផ្ដើមសម្រេចកិច្ចការទាំងអស់បន្ដិចម្ដងៗ ។ កិច្ចការរបស់យើងពុំមានព្រំដែននោះទេ ។...ជាតិសាសន៍ដែលបិទផ្លូវយើងពេលនេះនឹងបើកនៅថ្ងៃណាមួយ » ។[5] សព្វថ្ងៃនេះ យើងឃើញថា ការបំពេញពីការព្យាករណ៍ទាំងឡាយក្នុងព្រះគម្ពីរមរមនខិតកាន់តែជិតហើយ ៖

«ហើយ...ហេតុការណ៍នឹងកើតឡើងថាមហាក្សត្រទាំងឡាយនឹងបិទមាត់ខ្លួនជិត ត្បិតគេនឹងឃើញការណ៍ដែលឥតមានអ្នកណាប្រាប់ដល់គេឡើយ ហើយសេចក្ដីដែលគេមិនបានឮថ្លែងប្រាប់មកសោះ នោះគេនឹងបានយល់ច្បាស់វិញ ។ ត្បិតនៅថ្ងៃនោះដោយយល់ដល់រូបយើង នោះព្រះវរបិតាទ្រង់នឹងធ្វើកិច្ចការមួយដែលនឹងទៅជាកិច្ចការដ៏ធំ ហើយ អស្ចារ្យនៅក្នុងចំណោមពួកគេ» ។[6]

កិច្ចការរបស់ព្រះអម្ចាស់នេះគឺពិតជាធំ ហើយអស្ចារ្យ ប៉ុន្តែវារំកិលទៅមុខដោយគ្មានការកត់សម្គាល់ពីជាតិសាសន៍ ឆាកនយោបាយ វប្បធម៌ និងពួកអ្នកដឹកនាំសភាជាច្រើន ។ វារីកចម្រើនម្ដងម្នាក់ៗ និងមួយគ្រួសារៗ ដោយស្ងៀមស្ងាត់ និងសន្សឹមៗ សារលិខិតដ៏ពិសិដ្ឋរបស់វាគឺប្រទានពរជ័យដល់មនុស្សគ្រប់ទីកន្លែង ។

ខមួយនៅក្នុងព្រះគម្ពីរមរមនផ្ដល់នូវគន្លឹះមួយដល់ការរីកចម្រើនដ៏មហិមារបស់សាសនាចក្រសព្វថ្ងៃនេះ ។ «ហើយថែមទៀត យើងសូមប្រាប់អ្នកថា ថ្ងៃនោះនឹងមកដល់កាលណាការចេះដឹងពីព្រះអង្គសង្គ្រោះនឹងបានផ្សាយទូទៅ គ្រប់ទាំងសាសន៍ គ្រប់ពូជ មនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន» ។[7]

សារលិខិតដ៏សំខាន់បំផុតរបស់យើងដែលយើងត្រូវបានតែងតាំងដោយទេវភាព និងបានបញ្ជាឲ្យយកទៅគ្រប់ទីកន្លែងក្នុងពិភពលោកគឺថា ពិតជាមានព្រះអង្គសង្គ្រោះមែន ។ ទ្រង់បានរស់នៅក្នុងកាលដ៏ខ្ពស់បំផុត ។ ទ្រង់បានធ្វើឲ្យធួននិងអំពើបាបរបស់យើង ទ្រង់ត្រូវបានគេឆ្កាង ហើយទ្រង់ត្រូវបានរស់ឡើងវិញ ។ សាលិខិតដែលមិនអាចកាត់ថ្លៃបាន ដែលយើងប្រកាសដោយសិទ្ធិអំណាចពីព្រះ គឺជាហេតុដ៏ពិតដែលធ្វើសាសនាចក្រនេះរីកចម្រើនដូចដែលវារីកចម្រើន ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ទ្រង់បានយាងមកជួបយ៉ូសែប ស្ម៊ីធជាមួយនឹងព្រះវរបិតាទ្រង់។ ក្រោមការដឹកនាំរបស់ព្រះវរបិតា ទ្រង់បានស្ដាបនាដំណឹងល្អទ្រង់ឡើងវិញ ។ ទ្រង់បានបញ្ជូនពួកសាវក ព្យាការី កូនសោបព្វជិតភាពមកកាន់ផែនដីវិញ ។ ទ្រង់ដឹកនាំសាសនាចក្រទ្រង់តាមរយៈព្យាការីដែលនៅរស់ប្រធានថូម៉ាស អេស ម៉នសុន ។ សាសនាចក្រទ្រង់គឺជាថ្មដែលដាច់ផ្ដាច់ចេញពីភ្នំឥតដៃណាធ្វើដែលរមៀលទៅមុខទូទាំងពិភពលោក ។

យើងមានអំណរចំពោះយ៉ូសែប ស៊្មីធ ហើយយើងសម្លឹងដោយឆ្ងល់ដូចដែលឈ្មោះលោកត្រូវបានស្គាល់ គោរព មែនហើយថែមទាំងជេប្រមាថនៅទូទាំងផែនដី។ ប៉ុន្តែយើងទទួលស្គាល់ថាកិច្ចការដ៏មហិមានាថ្ងៃចុងក្រោយនេះគឺពុំមែនអំពីលោកទេ ។ វាជាកិច្ចការព្រះដ៏មានមហិទ្ធិឫទ្ធិ និងព្រះរាជបុត្រាទ្រង់ ជាម្ចាស់នៃមេត្រីភាព ។ ខ្ញុំថ្លែងទីបន្ទាល់ថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ ហើយខ្ញុំឈរជាមួយអ្នកដោយសេចក្ដីស្ញើច នៅពេលកិច្ចការនេះរំកិលឆ្ពោះទៅមុខដោយអព្ភូតហេតុ ដោយអស្ចារ្យ និងហួសពីការអត់ធ្មត់ ។ ជាការពិតណាស់ « ថ្ងៃនោះមក [ ដល់ ] កាលណាការចេះដឹងអំពីព្រះអង្គសង្គ្រោះ ...ផ្សាយទូទៅគ្រប់ទាំងសាសន៍ គ្រង់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន » ។ នេះជាថ្ងៃដែលប្រកបដោយពរជ័យ។ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ដានីយ៉ែល 2:28, 35, 44 សូមមើលផងដែរខទី 1--45។
2. យ៉ូសែប ស្ម៊ីធ---ប្រវត្តិ 1:33 ។
3. គោលលទ្ធិ និងសេចក្ដីសញ្ញា 65:2 ។
4. *Teachings of Presidents of the Church: Wilford Woodruff* ( ឆ្នាំ2004 ) ទំព័រ 25--26 ។
5. ហ្គរដុន ប៊ី ហ៊ិងគ្លី « The State of the Church» លីអាហូណា និង *Ensign* ខែវិច្ឆិកា ឆ្នាំ 2003 ទំព័រ 7 ។
6. នីហ្វៃទី3 21:8--9 ។
7. ម៉ូសាយ3:20 ។